*Kampuchean Action for Primary Education*

**អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា**

**ឯកសារយោង**

# ការបង្កើនការយល់ដឹងទៅលើអនាម័យ
# និង
# ការប្រើប្រាស់បង្គន់អនាម័យ

**( សេចក្តីព្រាង )**

**កំពង់ចាម , ខែ ៦ ២០០៣**

**ឧបត្ថម្ភគាំទ្រដោយអង្គការ យូនីសេហ្វ / ស៊ីដា**

# ការបង្កើនការយល់ដឹងនៅលើអនាម័យ និង ការប្រើប្រាស់បង្គន់អនាម័យ

## I. សេចក្តីផ្តើម :

បង្គន់ ដែលប្រកាន់ខ្ជាប់នូវភាពអនាម័យ គឺ ពិតជាមានសារៈសំខាន់ ជាពិសេសសម្រាប់កុមារីដែលពេញវ័យ ។ ឯកសារនេះ បានផ្តល់ជំនួយដល់នាយក- លោកគ្រូ -អ្នកគ្រូ ដើម្បីរៀបចំបង្គន់ប្រកបដោយអនាម័យសម្រាប់សិស្សានុសិស្ស និង គ្រូបង្រៀនទាំងអស់ ។ ដើម្បីណែនាំទៅលើផ្នែកនេះ សាលាត្រូវតែមានបង្គន់ និង ប្រភពទឹកក្នុងបរិវេណសាលារៀន ។ ក្នុងករណីដែលគ្មានបង្គន់ ឬ ប្រភពទឹក នាយកសាលា - លោកគ្រូ - អ្នកគ្រូ អាចចាត់សកម្មភាពរៀបចំបង្គន់ និង ប្រភពទឹក ដែលមានការចូលរួមគាំទ្រពីសហគមន៍ ជាមួយជំនួយពីអង្គការ អភិវឌ្ឍន៍ ដូចជា អង្គការ យូនីសេហ្វ ។

## II. គោលបំណង :

សិក្ខាកាម រៀបចំបង្គន់អនាម័យ បានសមស្រប ដែលអាចអោយសិស្សទាំងអស់ព្រមទាំង លោកគ្រូ - អ្នកគ្រូ ប្រើប្រាស់បង្គន់បានដោយងាយស្រួល និង ទៀងទាត់ ។

## III. រយៈពេល :

ការប្រជុំនេះ ត្រូវចំណាយពេល កន្លះ ថ្ងៃ ។

## IV. សម្ភារ :

- ក្រដាស A ៤
- ហ្វឺតក្តារខៀន
- ក្តារខៀន ស ។

## V. លំនាំបង្រៀន :

**1.** នាយកសាលា ត្រូវអញ្ជើញគ្រូទាំងអស់ នៅក្នុងសាលាមកចូលរួមប្រជុំ ដោយពន្យល់ថា សាលាត្រូវរៀបចំសកម្មភាពខ្លះ ៗ ដើម្បីបង្កើនផ្នែកអនាម័យ និង ការប្រើប្រាស់បង្គន់នៅក្នុងសាលា ។ នាយកសាលាត្រូវសួរសំណួរអោយគ្រូពិភាក្សាជាក្រុមតូចដូចខាងក្រោមនេះ ÷

- តើមានសារៈសំខាន់អ្វីខ្លះ ប្រសិនបើយើងមានបង្គន់ប្រកបដោយអនាម័យ ?

**ចម្លើយ** : បង្គន់ដែលមានអនាម័យល្អ អាចបង្កើនភាពទុកចិត្តដល់សិស្ស ចំពោះកុមារីដែលពេញវ័យដែលគេមករៀនទៀងទាត់ ដោយពុំមានអារម្មណ៍ខ្មាស់អៀន ដោយបានប្រើប្រាស់បង្គន់អនាម័យ ។ ក្នុងករណីដែលគ្រូមិនបានឆ្លើយតាមការរៀបរាប់ខាងលើនេះទេ នាយក ត្រូវប្រើសំណួរបំផុស ដើម្បីប្រមូលគំនិតខាងលើ ។

2. នាយកសាលា ត្រូវបញ្ជាក់ប្រាប់ថា មានសិស្សមួយចំនួននៅតែមិនប្រើប្រាស់បង្គន់ ។ នាយក ត្រូវរៀបចំសំណួរដូចខាងក្រោមសម្រាប់គ្រូពិភាក្សាជាក្រុមតូច ÷

- តើហេតុអ្វីបានជាសិស្សមួយចំនួនមិនប្រើប្រាស់បង្គន់ ?

**ចម្លើយ** : - បង្គន់មិនស្អាត
- សិស្សមិនយល់ពីរបៀបប្រើប្រាស់បង្គន់
- បង្គន់នៅឆ្ងាយ
- គ្មានទឹកនៅក្នុងបង្គន់
- បង្គន់ពុំមានសោសម្រាប់ចាក់
- បង្គន់មានសោ តែមានបញ្ហាផ្នែកកូនសោ
- បង្គន់ខូច ឬ បែកបាក់ ។

ប្រសិនបើគ្រូមិនបានឆ្លើយគំនិតយោបល់ដូចខាងលើនេះទេ នាយក ត្រូវសួរបំផុសដើម្បីអោយចេញនូវគំនិតខាងលើ ។

3. នាយកសាលា ពន្យល់ថា សាលានឹងផ្តល់សម្ភារដើម្បីសំអាតបង្គន់ ។ នាយក ត្រូវសួរសំណួរដូចខាងក្រោម ÷

- តើត្រូវធ្វើអ្វីខ្លះ ? និងត្រូវការសម្ភារអ្វីខ្លះ ? ដើម្បីធានាថាបង្គន់អាចដំណើរការទៅបានប្រកបដោយអនាម័យ ?

**ចម្លើយ** : - ផ្តល់សម្ភារសម្រាប់សំអាតបង្គន់ដូចជា ច្រាស់បង្គន់ , សាប៊ូលាងបង្គន់
- ទឹកសម្រាប់បង្ហូរលាងបង្គន់ និង លាងដៃបន្ទាប់ពីចេញពីបង្គន់
- សាប៊ូ និង កន្សែងសម្រាប់សំអាតដៃ
- ណែនាំសិស្សពីរបៀបប្រើប្រាស់បង្គន់ និង សម្ភារបង្គន់
- បែងចែកសិស្សដើម្បីបញ្ចូលទឹកទៅក្នុងបង្គន់អោយបានរាល់ថ្ងៃ
- បែងចែកវេនសំអាតជាប្រចាំ
- តាមដាន និង ត្រួតពិនិត្យ ថាតើបង្គន់ស្អាតហើយមានសាប៊ូ និង កន្សែងហើយឬនៅ ?

នាយកសាលាត្រូវកត់ត្រាចម្លើយលើក្តារខៀន ។ បើសិនការឆ្លើយរបស់គ្រូមិនត្រូវតាមចម្លើយខាងលើទេ នាយក អាចប្រើសំណួរបំផុសដើម្បីប្រមូលយកគំនិតដូចខាងលើ ។

4. នាយកត្រូវពន្យល់ថា សាលានឹងផ្តល់សម្ភារសម្រាប់សំអាតបង្គន់ ។ បន្ថែមលើសនេះទៅទៀត នាយកត្រូវធ្វើការពន្យល់ខ្លី ៗ នូវអ្វីដែលបានកត់ត្រានៅលើក្តារខៀន ។

- **ច្រាសបង្គន់** : បង្គន់នីមួយ ៗ ត្រូវបានផ្តល់ជូននូវច្រាស់មួយ ។ ចំពោះបង្គន់ណាដែលមានច្រាស់ចាស់ត្រូវប្តូរយកថ្មី ។

- **សាប៊ូបង្គន់** : បង្គន់នីមួយ ៗ ត្រូវបានផ្តល់ជូននូវសាប៊ូសម្រាប់សំអាតបង្គន់ផងដែរ ។
- **ទឹក** : ទឹកត្រូវតែមានអោយគ្រប់គ្រាន់សម្រាប់សំអាតបង្គន់ឬសិស្សត្រូវលាងសំអាតនៅពេលគេបន្ទោរបង់រួច ។
- **សាប៊ូលាងដៃ** : ត្រូវបានផ្តល់ជូនទៀងទាត់ផងដែរ (សម្រាប់បង្គន់នីមួយ ៗ ប៉ុន្តែនាយកសាលា ត្រូវប្រាកដថា សាប៊ូទាំងនេះងាយប្រើប្រាស់គ្រប់ពេល ។ គ្រូគួរតែបង្រៀនសិស្សពីរបៀបលាងដៃដោយសាប៊ូ ហើយពន្យល់ពីសារៈសំខាន់នៃការប្រើសាប៊ូ ។
- **កន្សែង** : តាមបង្គន់ក៏ត្រូវមានកន្សែងដើម្បីអោយសិស្សជូតសំអាតដៃរបស់គេ ហើយកន្សែងនេះត្រូវបោកគក់អោយបាន ១ ដង ឬ ២ ដង ក្នុងមួយសប្តាហ៍ជាមួយសាប៊ូ ធ្វើដូចនេះអាចធានាបានថាកន្សែងនេះគ្មានបង្កអោយមានជម្ងឺដល់សិស្ស ។ នាយក ឬ នាយករង ត្រូវទទួលខុសត្រូវទៅលើការសំអាតកន្សែងនេះ ប៉ុន្តែគាត់អាចអោយសិស្សណាម្នាក់យកកន្សែងនោះទៅបោកគក់នៅផ្ទះ ។

5. នាយកសាលា ត្រូវពន្យល់ថា ជារៀងរាល់ខែ គ្រូម្នាក់ ៗ ត្រូវបង្រៀនមេរៀនមួយ ឬ សកម្មភាពណាមួយដើម្បីជួយសិស្សពីរបៀបប្រើបង្គន់ ។ ការប្រជុំបច្ចេកទេសនៅថ្ងៃព្រហស្បតិ៍ គ្រូត្រូវកំណត់មេរៀនផ្សេង ៗ ដែលទាក់ទង និង សុខភាពក្នុងកម្មវិធីសិក្សា ។ ពេលប្រជុំនេះ គ្រូគួរតែរៀបចំកិច្ចតែងការបង្រៀនពីសុខភាព និង អនាម័យ ។ សកម្មភាពខាងក្រោមអាចបន្ថែមទៅក្នុងមេរៀនដើម្បីអោយរឹតតែមានលក្ខណៈជាកុមារមេត្រី ។

- **សកម្មភាពស្រាវជ្រាវ** : សិស្សអាចធ្វើការស្រាវជ្រាវនៅកន្លែងបន្ទប់អនាម័យ (ឧទាហរណ៍ : តើមានសិស្សប៉ុន្មាននាក់ដែលបានលាងដៃនិងសាប៊ូ បន្ទាប់ពីប្រើប្រាស់បង្គន់ ? តើមានទឹកគ្រប់គ្រាន់ដែរឬទេនៅក្នុងបង្គន់ ? ) បន្ទាប់មកបង្ហាញលទ្ធផល ។
- **គូររូបភាព** : កុមាររៀនថ្នាក់ទី ១ , ទី ២ , ទី ៣ និង ថ្នាក់ទី ៤ អាចគូររូបភាពផ្សេង ៗ គ្នាដោយទាក់ទងនិងការថែរក្សាបង្គន់ ។ សិស្សថ្នាក់ទី ៥ និង ថ្នាក់ទី ៦ អាចធ្វើជាផ្ទាំងរូបភាព ដែលបង្ហាញពតិមាន សុខភាព និង អនាម័យទៅនឹងបង្គន់អនាម័យ ។ ផ្ទាំងរូបភាពនេះ អាចដាក់បង្ហាញនៅក្នុងសាលា ឬ សហគមន៍( ប្រើក្តារខៀនផ្សព្វផ្សាយពតិមានរបស់សហគមន៍) ។
- **ល្ខោនត្រាប់** : ល្ខោនត្រាប់ គឺជាសកម្មភាពមួយដែលមនុស្សម្នាក់ព្យាយាមធ្វើកាយវិការ ឬ បង្ហាញតាមរយៈទឹកមុខ ដោយមិននិយាយហើយអ្នកផ្សេងទៀត អាចទស្សន៍ទាយ ឬ សន្និដ្ឋានថា ជាអ្វី ? ។ សិស្សអាចធ្វើល្ខោនត្រាប់ដែលទាក់ទងនិងបង្គន់អនាម័យ (ដូចជា បង្ហាញការចូល-ចេញ -បិទ ឬ បើកទ្វារបង្គន់-លាងបង្គន់ប្រើប្រាស់សំអាតបង្គន់-លាងដៃ-ប្រើកន្សែងជូតដៃ ។ល ។) សិស្សផ្សេងទៀតនៅក្នុងថ្នាក់ អាចទាយសកម្មភាពរបស់ល្ខោនត្រាប់នេះ ថាគេកំពុងធ្វើអ្វី ?
- **ការសម្តែងតួ** : គ្រូអាចរៀបចំសម្តែងតួ ដោយផ្តោតទៅលើបង្គន់អនាម័យ ។

6. នាយកសាលា ត្រូវពន្យល់អំពីភារកិច្ច និង ការទទួលខុសត្រូវ :

- រៀងរាល់ថ្ងៃ គ្រូថ្នាក់ទី ៦ គួរចាត់តាំងសិស្ស ២ នាក់ ទៅ ៥ នាក់ដើម្បីបញ្ចូលទឹកទៅក្នុងបង្គន់ ។ គ្រូត្រូវ

រៀបចំកាលវិភាគប្រចាំថ្ងៃ ឬ សប្តាហ៍ ដែលអាចផ្តល់ឱកាសអោយសិស្សផ្សេងទៀត បានចូលរួមក្នុងសកម្មភាព នេះ ។ កាលវិភាគត្រូវតែដាក់បង្ហាញនៅក្នុងបន្ទប់រៀន ។

- សិស្សថ្នាក់ទី ៦ ដែលត្រូវបញ្ចូលទឹកក្នុងបង្គន់ក៏ត្រូវលាងសំអាតបង្គន់ផងដែរ ។
- នាយកសាលា , នាយករងសាលា ត្រូវពិនិត្យតាមដានអោយបានម៉ត់ចត់ជារៀងរាល់ថ្ងៃ ក្រែងការសំអាតរបស់គេពុំបានល្អ ឬ គ្មានទឹកសម្រាប់ប្រើគ្រប់គ្រាន់ ។ នាយក នាយករង ត្រូវពិនិត្យច្រាស់.សាប៊ូ.សាប៊ូលាងបង្គន់ថាតើកំពុងប្រើប្រាស់ ឬ មួយពុំមានសម្ភារសម្រាប់ប្រើប្រាស់ ។

7. នាយកសាលា បិទការប្រជុំ ហើយត្រូវបញ្ជាក់ឡើងវិញដល់គ្រូទាំងអស់ថា បង្គន់ដែលប្រកបដោយអនាម័យគឺជាកត្តាចង្អុលបង្ហាញមួយ នៅក្នុងឧបករណ៍វាយតម្លៃសាលាកុមារមេត្រី ។ នាយកសាលាត្រូវផ្សព្វផ្សាយដល់គ្រូទាំងអស់ ត្រូវព្យាយាមអោយអស់លទ្ធភាពដើម្បីធានាថា មុខជានឹងបានពិន្ទុល្អ ក្នុងការវាយតម្លៃនៅពេលខាងមុខ ។

<u>**ចំណាំ**</u> :

- ក្នុងករណីដែលសាលាបានបង្កើតសមាគមសិស្ស គេអាចជួយដល់គ្រូ ព្រមទាំងនាយក ដើម្បីអនុវត្តន៏សកម្មភាពនេះ ។
- កាកបាទក្រហម មានផ្ទាំងរូបភាពល្អ ៗ ជាច្រើនអំពីការប្រើប្រាស់បង្គន់អនាម័យ ។ ផ្ទាំងរូបភាព
- ទាំងនេះ អាចរកទិញបានតាមរយៈ យូនីសេហ្វ ក្រុមការងារតាមខេត្ត ឬ ខេប ។